ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តពោធិ៍សាត់

សំណុំរឿងព្រហ្មទណ្ឌលេខ ៨០
ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២
សាលក្រមលេខ : ៤៤ (ត)
ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តពោធិ៍សាត់

-បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តពោធិ៍សាត់ នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ៨:៣០នាទីព្រឹក ។

-ដោយមានសមាសភាពដូចខាងក្រោម:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងខេត្តពោធិ៍សាត់ និងជាចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តពោធិ៍សាត់

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៨០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០២២ របស់អយ្យការអមសាលាដំបូងខេត្ត ពោធិ៍សាត់ ។

-ឈ្មោះ [redacted] ម៉ាកគីជេន (MARKEY III [redacted]) ភេទប្រុស អាយុ៥៩ឆ្នាំ ជនជាតិអាមេរិកកាំង មុខរបរ បើករីសត ទីកន្លែងកំណើតនៅ [redacted] សហរដ្ឋអាមេរិក ទី[illegible] បច្ចុប្បន្នភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ស្ថានភាពគ្រួសារ : រៀបការ [illegible] ឈ្មោះ [redacted] ម៉ាកគី មានកូនចំនួន០១នាក់ ឪពុកឈ្មោះ MARKEY II [redacted] (ស) [illegible] ឈ្មោះ [redacted] KOSTECKA (រ) ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

ពីបទ : ហិង្សាដោយចេតនា ប្រព្រឹត្តនៅចំណុចភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ២៣ ខែមករា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

ច្បាប់ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ពោធិ៍សាត់ ថ្ងៃ ២៥.មករា ឆ្នាំ ២០២៣
ក្រឡាបញ្ជី

[redacted]

Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វីរៈបុត្រ ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មាន អាសយដ្ឋាននៅផ្ទះលេខ១៣៧៧ ផ្លូវលំ ភូមិត្រា៤ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

-លោក [redacted] ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ផាន់ វីរៈបុត្រ ។

-លោក [redacted] ជាមេធាវី ការពារសិទ្ធិឲ្យជនជាប់ចោទ ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:**

កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២២ នៅចំណុចភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្ត ពោធិ៍សាត់ វេលាម៉ោង១៣និង៣០នាទី កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលអន្លង់រាប និងមេភូមិដីក្រហម បាន ចុះទៅធ្វើការសម្របសម្រួលករណីជនជាប់ចោទឈ្មោះ [redacted] ម៉ាកគីជេន (MARKEY III [redacted] JANES) ដាំបង្គោលរបងលើព្រំដីរបស់ខ្លួនដោយមានការដាំមិនប្រក្រតី (ចូលដីផ្លូវលំ) ពេលនោះមាន ឈ្មោះ [redacted] វីរៈបុត្រ ដែលមានព្រំដីជាប់គ្នាបានដើរចូលទៅមើលដែរ តែជនជាប់ចោទឈ្មោះ [redacted] ម៉ាកគីជេន (MARKEY III [redacted] បានឈរពាំងមិនឲ្យឈ្មោះ [redacted] វីរៈបុត្រ ចូលទៅមើល នោះទេ បន្ទាប់មកឈ្មោះ [redacted] វីរៈបុត្រ និងឈ្មោះ [redacted] ម៉ាកគីជេន (MARKEY III [redacted] JANES) បាននិយាយជជែកគ្នាខ្លាំងៗ បន្តិចក្រោយមកឈ្មោះ [redacted] វីរៈបុត្រ ក៏បានរអិលជើងដួលអុក គូទ នៅនឹងកន្លែងកើតហេតុ ។

-បានឃើញ ដីកាសន្និដ្ឋានចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ១៣១២ អក/២២ ចុះ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តពោធិ៍សាត់ ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះផ្ទាល់លេខ ៥៩៨ ពសប្រធ/២២ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តពោធិ៍សាត់ ។

**សំអាងហេតុ**

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿងត្រឹមត្រូវតាមច្បាប់
-ក្រោយពីបានស្តាប់ចម្លើយចុងក្រោយរបស់ជនជាប់ចោទ

**ឃើញថា**

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ម៉ាកគីជេន (MARKEY III [redacted] បានឆ្លើយថា : នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២២ វេលាម៉ោងប្រហែល២នាទីរសៀល គឺខ្លួនដើរមើលព្រំ ដីដែលត្រូវគេបើកប៉ះបុក ដួលបង្គោលរបង ហើយពេលនោះក៏មានសមត្ថកិច្ចចុះមកដែរ ឃើញបង្គោល ដួល តែអត់ដឹងថាអ្នកណាជាអ្នកបុកប៉ះទេ ។ ចំពោះព្រំដីរបស់ខ្លួនមានបោះបង្គោលរួចហើយ ភូមិបាល ហើយបង្គោលរបងព្រំដីរបស់ខ្លួន ខ្លួនធ្វើនេះមិនមានបំណងចូលទៅដីសាធារណៈនោះទេ ។ នៅ



បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ពោធិ៍សាត់ ថ្ងៃ ២៥. មករា ២០២៣
ក្រឡាបញ្ជី
[redacted]

Scanned with CamScanner

មុនកើតហេតុមួយថ្ងៃ នៅវេលាម៉ោង៥នាទីរសៀល កូនចៅរបស់ឈ្មោះ [redacted] វីរៈបុត្រ បានយកត្រាក់ទ័រចូលទៅធ្វើការឈូសឆាយផ្លូវ ដោយពេលមេឃងងឹតខ្លួនបានប្រាប់គាត់ឲ្យចេញទៅក្រៅវិញ ដោយសារកម្មកររបស់ខ្លួនក៏ទៅទីនោះដែរ ខ្លាចមានគ្រោះថ្នាក់ដោយប្រការណាមួយ ហើយឈ្មោះ [redacted] វីរៈបុត្រ ក៏ខឹង ។ នៅមុនកើតហេតុ១ថ្ងៃបង្គោលរបងនេះត្រូវបានអ្នកបើកអាប៉ិលបើកបុកបណ្តាលឲ្យដួល ហើយខ្លួនក៏បានយកបង្គោលរបងទៅដាំនៅកន្លែងដដែល ។ នៅពេលខ្លួនទៅដាំបង្គោលនោះគ្មានអ្នកណាមករករឿងអ្វីនោះទេ តែបែរជាខាងកាហ្វេភ្នំរករឿងខ្លួនទៅវិញ ។ នៅថ្ងៃដែលខ្លួនដាំបង្គោលមិនមានអ្នកណាមកហាមឃាត់នោះទេ ស្រាប់តែស្អែកឡើងនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២២ មានត្រាក់ទ័រមកឈូសប៉ះបង្គោលរបស់ខ្លួន ហើយខ្លួនអត់ដែលមានជម្លោះជាមួយអ្នកធ្វើផ្លូវនោះទេ ។ នៅថ្ងៃកើតហេតុនេះដែរ ស្រាប់តែមេភូមិហៅប្រពន្ធរបស់ខ្លួនចេញមកដោះស្រាយ ពេលដោះស្រាយនោះមិនមានជម្លោះនោះទេ ។ ខ្លួនមិនធ្លាប់មានជម្លោះជាមួយឈ្មោះ [redacted] វីរៈបុត្រ នោះទេ តែពេលនោះខ្លួនលឺគេស្រែកឡូឡា ដោយខ្លួនមិនយល់ពីភាសាខ្មែរ មិនដឹងថាស្រែកឡូឡាសំដៅទៅអ្នកណា ។ នៅថ្ងៃកើតហេតុនោះខ្លួន និងឈ្មោះ [redacted] វីរៈបុត្រ គ្រាន់តែជជែកគ្នា ហើយឈ្មោះ [redacted] វីរៈបុត្រ ដើរមករកខ្លួន ពេលនោះខ្លួនថយក្រោយស្រាប់តែលឺសូថាឈ្មោះ [redacted] វីរៈបុត្រ ដួល ហើយខ្លួនក៏មិនបានដឹងថាគេដួលយ៉ាងម៉េចដែរ ។ ចំពោះឈ្មោះ [redacted] វីរៈបុត្រ ដួលទៅនឹងដីនោះ គឺដីមានរាងជំរាល ហើយឈ្មោះ [redacted] វីរៈបុត្រ ឈរនៅខាងលើ ខ្លួនឈរនៅខាងក្រោម ហើយនៅពេលដែលឈ្មោះ [redacted] វីរៈបុត្រ ដួលភ្លាម ស្រាប់តែមានសមត្ថកិច្ចម្នាក់មកចាប់កដៃខ្លួនចេញ ពេលនោះខ្លួនគ្រាន់តែបង្វិលខ្លួនចេញ ហើយឈ្មោះ [redacted] វីរៈបុត្រ ក៏បានងើបឡើងធម្មតា មិនមានស្នាមរបួសអ្វីនោះទេ ។ ខ្លួនមិនបានក្រវាសដៃមកក្រោយទេ ហើយខ្លួនក៏មិនបានប៉ះទៅលើជនរងគ្រោះដែរ ខ្លួនស្គាល់ជនរងគ្រោះព្រោះផ្ទះនៅក្បែរគ្នា ដោយគាត់ជាម្ចាស់ហាងការហ្វេភ្នំ ហើយឈ្មោះ [redacted] វីរៈបុត្រ ធ្លាប់បានបោះចោលសំរាមចូលក្នុងដីរបស់ខ្លួន ។ ខ្លួនឯកភាពសុំបញ្ចប់រឿងជាមួយឈ្មោះ [redacted] វីរៈបុត្រ ។

-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វីរៈបុត្រ បានឆ្លើយបញ្ជាក់ថា : នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២២ ខ្លួនបានឃើញបង្គោលរបងមួយដាំមិនប្រក្រតី ខ្លួនបានហៅមេភូមិ មេប៉ុស្តិ៍ មកមើល ពេលនោះមានជនជាប់ចោទឈ្មោះ [redacted] ម៉ាកគីជេន (MARKEY III [redacted] JANES) មកដែរ បានវាយខ្លួនមួយកែងដៃ បណ្តាលឲ្យខ្លួនដួល ដោយគាត់បានជាន់ជើង រួចអុកកែងបណ្តាលឲ្យខ្លួនដួលអុកគូទ (នៅពេលនោះមានមេភូមិ និងមន្ត្រីប៉ុស្តិ៍) ។ ចំពោះការបោះបង្គោលថ្មីនេះ មិនប៉ះពាល់អ្វីដល់ខ្លួនទេ ចំពោះខ្លួនគ្រាន់តែបោះទៅមិនប្រក្រតីតែប៉ុណ្ណោះ ។ នៅពេលកើតហេតុនោះខ្លួនមិនបានដើរទៅរកជនជាប់ចោទឈ្មោះ ថមម៉ាស ម៉ាកគីជេន (MARKEY III [redacted] JANES) ទេគឺគាត់ជាអ្នកដើរមករកខ្លួន ពេលដើរដល់មុខខ្លួន គាត់បានយកជើងខាងស្តាំរបស់គាត់ ជាន់ជើងខាងឆ្វេងខ្លួន ហើយដៃស្តាំអុកមួយកែងចំខ្លួន បណ្តាលឲ្យដួលអុកគូទ ពេលដួលហើយខ្លួនបានងើបវិញធម្មតា ។ នៅពេលកើតហេតុនោះមានមនុស្សច្រើនប្រហែល៧នាក់ ហើយគ្នាខ្លួនមានកូនចៅម្នាក់ធ្វើការលើកាហ្វេភ្នំ ខ្លួនជាអ្នកគ្រប់គ្រងនៅទីនោះ នៅថ្ងៃកើតហេតុមានត្រាក់ទ័ររបស់ខ្លួនទៅឈូសដី។ក្នុងរឿងនេះខ្លួនឯកភាពសុំបញ្ចប់រឿងជាមួយឈ្មោះ [redacted] ម៉ាកគីជេន (MARKEY III [redacted] JANES) ដោយរូបគាត់និងខ្លួនជាអ្នករស់នៅជិតខាងនឹងគ្នា ។



បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃទី ២៥ ... ២០២៣

[redacted]

Scanned with
CamScanner

-តាមចម្លើយសាក្សីឈ្មោះ [redacted] ម៉ាកគី ប្រពន្ធរបស់ជនជាប់ចោទបានឆ្លើយបញ្ជាក់ថា : នៅថ្ងៃកើតហេតុថ្ងៃទី២៣ ខែមករា ឆ្នាំ២០២២ ខ្លួននៅកន្លែងនោះ ដំបូងឡើយខ្លួនឃើញឈ្មោះ [redacted] វីរៈបុត្រ មករករឿង រឿងព្រំដីរបស់ខ្លួន ហើយខ្លួនឃើញជនរងគ្រោះដើរសំដៅទៅរកប្តីរបស់ខ្លួន និងបានបុកខ្នងប្តីខ្លួន ពេលនោះប្តីរបស់ខ្លួនក៏បានងាកមកឃើញដួលហើយ ហើយពេលដួលនោះខ្លួនឃើញឈ្មោះ ប្រុក ចាន់ ជាអ្នកលើកជនរងគ្រោះឡើង ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] ចាន់ បានឆ្លើយបញ្ជាក់ថា : នៅថ្ងៃកើតហេតុខ្លួននៅកន្លែងនោះ នៅជាប់ជាមួយឈ្មោះ [redacted] វីរៈបុត្រ ខ្លួនឃើញឈ្មោះ [redacted] វីរៈបុត្រ ដើរអុកគួទខ្លួនឯង ចំណែកឈ្មោះ [redacted] ម៉ាកគីជេន ( MARKEY III [redacted] JANES ) ឈរពីរម៉ែត្រពីគ្នា ហើយពេលឈ្មោះ [redacted] វីរៈបុត្រ ដួលអុកគួទនោះ មិនមានស្នាមរបួសទេ គាត់ដួល ខ្លួនឯងទេ ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] អែម បានឆ្លើយបញ្ជាក់ថា : នៅថ្ងៃកើតហេតុខ្លួនក៏បាននៅទីនោះដែរ ខ្លួនឃើញជនជាប់ចោទ និងជនរងគ្រោះជជែកគ្នាតិចតួចទេ ដោយឈរនៅចម្ងាយពីគ្នាប្រហែលពីរទៅបីម៉ែត្រ ពេលនោះខ្លួនឃើញជនរងគ្រោះដួលម្នាក់ឯង ដោយជនរងគ្រោះឈរនៅខាងក្រោយកូនប្រសាររបស់ខ្លួន ( ជនជាប់ចោទ ) ។ ខ្លួនបានឃើញជនរងគ្រោះដួលអុកគួទតែម្នាក់ឯងទេ ជនជាប់ចោទមិនបានធ្វើសកម្មភាពជាន់ជើង និងវាយកែងនោះទេ ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា : ខ្លួនជាមេភូមិ ដោយនៅថ្ងៃកើតហេតុខ្លួនក៏បាននៅទីនោះដែរ ដោយខ្លួនដើរសម្របសម្រួលបញ្ហាធ្វើផ្លូវ ដោយគេធ្វើផ្លូវរបស់គេ តែឈ្មោះ [redacted] ម៉ាកគីជេន ( MARKEY III [redacted] JANES ) មិនឲ្យគេធ្វើតែម្តង ។ ពេលខ្លួនទៅដល់ដំបូង ឃើញមានមាត់តូចមាត់ធំដាក់គ្នារួចហើយ រួចហើយដើរចុះឡើងដោយឈ្មោះ [redacted] ម៉ាកគីជេន ( MARKEY III [redacted] JANES ) បានឈរពាំងមិនឲ្យឈ្មោះ [redacted] វីរៈបុត្រ ដើរចូល ពេលនោះខ្លួនឃើញឈ្មោះ [redacted] ម៉ាកគីជេន ( MARKEY III [redacted] JANES ) ឈរពាំងចុះឡើងក៏ឃើញឈ្មោះ [redacted] វីរៈបុត្រ ដួល ហើយឈ្មោះ [redacted] ម៉ាកគីជេន ( MARKEY III [redacted] JANES ) ដើរចេញ ។ ខ្លួនមិនបានឃើញឈ្មោះ [redacted] វាយទៅលើឈ្មោះ [redacted] វីរៈបុត្រ នោះទេ ដោយឈ្មោះ [redacted] វីរៈបុត្រ ដួលខ្លួនឯង ហើយនៅចំណុចដីនេះមានវាងចោទបន្តិច ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] ឡៃហ៊ិន បានឆ្លើយបញ្ជាក់ថា : ខ្លួនជាមេប៉ុស្តិ៍ ដោយនៅថ្ងៃកើតហេតុខ្លួនបានចុះទៅដល់ទីតាំងកើតហេតុ ពេលខ្លួនចុះទៅដល់មិនទាន់មានទំនាស់អ្វីនោះទេ ឃើញឈ្មោះ [redacted] ម៉ាកគីជេន ( MARKEY III [redacted] JANES ) និងឈ្មោះ [redacted] វីរៈបុត្រ ជជែកគ្នាលឺខ្លាំងៗ ។ ខ្លួនមិនបានឃើញឈ្មោះ [redacted] ម៉ាកគីជេន ( MARKEY III [redacted] JANES ) ជាន់ជើង ឬ យ៉ាងណានោះទេ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន ក្រោយពីបានពិភាក្សាដេញដោលចំពោះមុខនាពេលសវនាការបានច្រើនហើយនោះ ឃើញថាភាគីដើមបណ្តឹង និងជនជាប់ចោទ មានការសម្របសម្រួលគ្នាក្នុង

បានចតចម្លងត្រឹមត្រូវតាមច្បាប់ដើម

២៥.មករា ២០២៣

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner

ពេលសវនាការ ដោយដើមបណ្តឹងរដ្ឋប្បវេណីមិនទាមទារអ្វីទាំងអស់ ហើយបានសុំអោយតុលាការបញ្ចប់រឿង ដោយភាគីទាំងពីរស្រុះស្រួលគ្នា ដូចនេះសូមលោកចៅក្រមសម្រេចតាមច្បាប់ ។

-លោក [redacted] មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋាន ខ្លួនសុំយល់ព្រមតាមឆន្ទៈរបស់កូនក្តីខ្លួន ដោយគាត់ចង់បញ្ចប់រឿង និងចង់សម្របសម្រួលជាមួយភាគីជនជាប់ចោទ ដូចនេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំតុលាការសម្រេចតាមឆន្ទៈរបស់កូនក្តីខ្លួនដោយក្តីអនុគ្រោះ ។

-លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋាន ដោយកូនក្តីរបស់ខ្លួនគ្រាន់តែកាពារព្រំដីរបស់គាត់តែប៉ុណ្ណោះ ម៉្យាងពេលសវនាការនេះ ភាគីទាំងពីរមានបំណងបញ្ចប់រឿងដោយស្រុះស្រួលគ្នាវិញ មិនទាមទារសំណងអ្វីឡើយ ដូចនេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ស្នើសុំតុលាការមេត្តាសម្រេចតាមគូភាគី ដែលបានស្រុះស្រួលគ្នា និងសុំឲ្យតុលាការលើកលែងចោទប្រកាន់លើកូនក្តីរបស់ខ្លួន ។

-តាមការបញ្ជាក់របស់ជនជាប់ចោទឈ្មោះ [redacted] ម៉ាកគីជេន (MARKEY III [redacted] JANES) ឃើញថា : នៅមុនថ្ងៃកើតហេតុមួយថ្ងៃខ្លួនបានដាំបង្គោលរបងរបស់ខ្លួន លុះនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២២ ខ្លួនបានទៅមើលព្រំរបងខ្លួនម្តងទៀតដោយមានគេឈូស ពេលនោះមានអាជ្ញាធរភូមិ ឃុំ មេប៉ុស្តិ៍ រួមទាំងមានឈ្មោះ [redacted] វីរៈបុត្រ មកដែរ ។ ពេលនៅមើលដីនោះខ្លួន និងឈ្មោះ [redacted] វីរៈបុត្រ បានជជែកគ្នា ហើយឈ្មោះ [redacted] វីរៈបុត្រ បានដើរមករកខ្លួន ពេលនោះខ្លួនថយក្រោយស្រាប់តែលឺសូរថាឈ្មោះ [redacted] វីរៈបុត្រ ដួល ហើយខ្លួនក៏មិនបានដឹងថាគេដួលយ៉ាងម៉េចដែរ ។ ចំពោះឈ្មោះ [redacted] វីរៈបុត្រ ដួលទៅនឹងដីនោះ គឺដីមានរាងជំរាល ហើយឈ្មោះ [redacted] វីរៈបុត្រ ឈរនៅខាងលើ ខ្លួនឈរនៅខាងក្រោម ។

-តាមការបញ្ជាក់របស់សាក្សីឈ្មោះ [redacted] ម៉ាកគី សាក្សីឈ្មោះ [redacted] ចាន់ សាក្សីឈ្មោះ [redacted] អែម សាក្សីឈ្មោះ [redacted] វួ និងសាក្សីឈ្មោះ [redacted] ឡៃហ៊ីន បានឆ្លើយប្រហាក់ប្រហែលគ្នាថា ខ្លួនបានឃើញឈ្មោះ [redacted] ម៉ាកគីជេន (MARKEY III [redacted] JANES) និងឈ្មោះ [redacted] វីរៈបុត្រ ឈរជជែកគ្នា ក្រោយមកបានឃើញឈ្មោះ [redacted] វីរៈបុត្រ ដួលអុកគូទតែម្នាក់ឯង មិនបានឃើញឈ្មោះ [redacted] ម៉ាកគីជេន (MARKEY III [redacted] JANES) ជាន់ជើង ឬវាយកែងទៅលើឈ្មោះ [redacted] វីរៈ នោះទេ ហើយស្ថានភាពដីនោះមានរាងជំរាល ។

-គូភាគីជាអ្នករស់នៅជិតខាងនឹងគ្នា មិនចង់អោយមានទំនាស់នឹងគ្នាវែងឆ្ងាយ ហើយបានឯកភាពបញ្ចប់រឿងក្តីនេះ ម៉្យាងទៀតព្យសនកម្មដែលកើតមានចំពោះជនរងគ្រោះមានតំរិតស្រាល ដូចនេះតុលាការ និងសម្រេចឲ្យជនជាប់ចោទឈ្មោះ [redacted] ម៉ាកគីជេន (MARKEY III [redacted] JANES) រួចផុតពីបទចោទ ។

បានចតចម្លងត្រឹមត្រូវតាមច្បាប់ដើម

២៥.មករា ២០២៣

ក្រឡាបញ្ជី



[redacted]

**ហេតុដូច្នេះតុលាការ**

**វិនិច្ឆ័យសេចក្តី**

១.ឲ្យឈ្មោះ [redacted] ម៉ាកគីជេន ( MARKEY III THOMAS JANES ) ភេទប្រុស អាយុ៥៩ ឆ្នាំ ជនជាតិអាមេរិកកាំង រួចខ្លួនពីបទ : ហិង្សាដោយចេតនា ប្រព្រឹត្តនៅចំណុចភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ២៣ ខែមករា ឆ្នាំ២០២២ ។

២.សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខានិងត្រា
[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខានិងត្រា
[redacted]

---

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ១៥កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
ពោធិ៍សាត់,ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ពោធិ៍សាត់ ថ្ងៃ ២៥.មករា ២០២៣
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner